# ឧទាហរណ៍នៃភាពខ្លួនទីពឹងខ្លួនមកពីប្រវត្តិសាស្ត្រសាសនាចក្រ

ម៉ាទិន ហារិស ៖ នៅក្នុងឆ្នាំ១៨២៧ យ៉ូសែប ស្ម៊ីធ បានប្រឈមមុខនឹងការបៀតបៀន និងភាពក្រីក្រ នៅពេលលោកបានព្យាយាមបកប្រែព្រះគម្ពីរមរមនពីផ្ទាំងមាស ។ ម៉ាទិន ហារិស ជាកសិករជោគជ័យម្នាក់ បានដឹងពីស្ថានភាពរបស់យ៉ូសែប ។ សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦១–៦២ ដោយរកមើលពីរបៀបដែល ម៉ាទិន អាចជួយ យ៉ូសែប ស្ម៊ីធ ។ សូមអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ១៩:២៦, ៣៤–៣៥; ១០៤:២៦ ដើម្បីមើលពីរបៀបផ្សេងទៀតដែល ម៉ាទិន ហារិស អាចបម្រើព្រះអម្ចាស់ និងផ្ដល់ពរដល់អ្នកដទៃ ។ ម៉ាទិនបានបង្កើតភាពខ្លួនទីពឹងខ្លួនផ្នែកហិរញ្ញវត្ថុដែលចាំបាច់ដើម្បីបម្រើព្រះអម្ចាស់ និងអ្នកដទៃតាមរបៀបដ៏មានអត្ថន័យ ។ តើក្មេងជំទង់អាចធ្វើអ្វីខ្លះនៅពេលនេះ ដើម្បីអភិវឌ្ឍជំនាញ ការអប់រំ និងមធ្យោបាយផ្សេងៗដើម្បីជួយពួកគេបម្រើព្រះអម្ចាស់ និងអ្នកដទៃទៀតនៅពេលអនាគត ?

អែមម៉ា ហេល ស្ម៊ីធ ៖ នៅពេលគាត់បានជួប យ៉ូសែប ស្ម៊ីធ អិមម៉ា ហេល គឺជាអ្នកអាន អ្នកនិពន្ធ គ្រូបង្រៀន និងតន្ត្រីការនីដែលមានស្នាដៃមួយរូប ។ សូមអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ២៥:៥–៧, ១១ ដោយរកមើលការទទួលខុសត្រូវដែលព្រះអម្ចាស់បានប្រគល់ដល់អិមម៉ា ។ អិមម៉ាបានអភិវឌ្ឍជំនាញ និងការអប់រំ ដែលបានជួយគាត់បម្រើព្រះអម្ចាស់ និងអ្នកដទៃតាមរបៀបដ៏មានអត្ថន័យ ។ តើក្មេងជំទង់អាចធ្វើអ្វីខ្លះនៅពេលនេះ ដើម្បីអភិវឌ្ឍជំនាញ ការអប់រំ និងមធ្យោបាយផ្សេងៗដើម្បីជួយពួកគេបម្រើព្រះអម្ចាស់ និងអ្នកដទៃទៀតនៅពេលអនាគត ?

វិលលាម ដ័បបុលយូ ហ្វែប្ស ៖ ព្រះអម្ចាស់បានណែនាំ វិលលាម ដ័បបុលយូ ហ្វែប្ស ដែលជាអ្នកប្រែចិត្តជឿថ្មីចូលសាសនាចក្រ ឲ្យផ្លាស់ទៅរដ្ឋមិសសួរី ។ សូមអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ៥៥:៤ និង ៥៧:១១–១៣ ដោយរកមើលកិច្ចការពិសេសដែលព្រះអម្ចាស់បានប្រទានដល់វិលលាម ឲ្យបម្រើក្នុងសាសនាចក្ររបស់ទ្រង់ ។ សូមប្រើលិបិក្រម « Authors and Composers » នៅក្នុងសៀវភៅទំនុកតម្កើងដើម្បីស្វែងរកទំនុកតម្កើងដែល វិលលាម ដ័បបុលយូ ហ្វែប្ស បានសរសេរ ដែលបន្តផ្ដល់ពរដល់សាសនាចក្រសព្វថ្ងៃនេះ ។ វិលលាម បានអភិវឌ្ឍជំនាញ និងការអប់រំ ដែលបានជួយគាត់បម្រើព្រះអម្ចាស់ និងអ្នកដទៃតាមរបៀបដ៏មានអត្ថន័យ ។ តើក្មេងជំទង់អាចធ្វើអ្វីខ្លះនៅពេលនេះ ដើម្បីអភិវឌ្ឍជំនាញ ការអប់រំ និងមធ្យោបាយផ្សេងៗដើម្បីជួយពួកគេបម្រើព្រះអម្ចាស់ និងអ្នកដទៃទៀតនៅពេលអនាគត ?


# ឧទាហរណ៍នៃភាពខ្លួនទីពឹងខ្លួនមកពីប្រវត្តិសាស្ត្រសាសនាចក្រ

ម៉ាទិន ហារិស ៖ នៅក្នុងឆ្នាំ១៨២៧ យ៉ូសែប ស្ម៊ីធ បានប្រឈមមុខនឹងការបៀតបៀន និងភាពក្រីក្រ នៅពេលលោកបានព្យាយាមបកប្រែព្រះគម្ពីរមរមនពីផ្ទាំងមាស ។ ម៉ាទិន ហារិស ជាកសិករជោគជ័យម្នាក់ បានដឹងពីស្ថានភាពរបស់យ៉ូសែប ។ សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦១–៦២ ដោយរកមើលពីរបៀបដែល ម៉ាទិន អាចជួយ យ៉ូសែប ស្ម៊ីធ ។ សូមអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ១៩:២៦, ៣៤–៣៥; ១០៤:២៦ ដើម្បីមើលពីរបៀបផ្សេងទៀតដែល ម៉ាទិន ហារិស អាចបម្រើព្រះអម្ចាស់ និងផ្ដល់ពរដល់អ្នកដទៃ ។ ម៉ាទិនបានបង្កើតភាពខ្លួនទីពឹងខ្លួនផ្នែកហិរញ្ញវត្ថុដែលចាំបាច់ដើម្បីបម្រើព្រះអម្ចាស់ និងអ្នកដទៃតាមរបៀបដ៏មានអត្ថន័យ ។ តើក្មេងជំទង់អាចធ្វើអ្វីខ្លះនៅពេលនេះ ដើម្បីអភិវឌ្ឍជំនាញ ការអប់រំ និងមធ្យោបាយផ្សេងៗដើម្បីជួយពួកគេបម្រើព្រះអម្ចាស់ និងអ្នកដទៃទៀតនៅពេលអនាគត ?

អែមម៉ា ហេល ស្ម៊ីធ ៖ នៅពេលគាត់បានជួប យ៉ូសែប ស្ម៊ីធ អិមម៉ា ហេល គឺជាអ្នកអាន អ្នកនិពន្ធ គ្រូបង្រៀន និងតន្ត្រីការនីដែលមានស្នាដៃមួយរូប ។ សូមអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ២៥:៥–៧, ១១ ដោយរកមើលការទទួលខុសត្រូវដែលព្រះអម្ចាស់បានប្រគល់ដល់អិមម៉ា ។ អិមម៉ាបានអភិវឌ្ឍជំនាញ និងការអប់រំ ដែលបានជួយគាត់បម្រើព្រះអម្ចាស់ និងអ្នកដទៃតាមរបៀបដ៏មានអត្ថន័យ ។ តើក្មេងជំទង់អាចធ្វើអ្វីខ្លះនៅពេលនេះ ដើម្បីអភិវឌ្ឍជំនាញ ការអប់រំ និងមធ្យោបាយផ្សេងៗដើម្បីជួយពួកគេបម្រើព្រះអម្ចាស់ និងអ្នកដទៃទៀតនៅពេលអនាគត ?

វិលលាម ដ័បបុលយូ ហ្វែប្ស ៖ ព្រះអម្ចាស់បានណែនាំ វិលលាម ដ័បបុលយូ ហ្វែប្ស ដែលជាអ្នកប្រែចិត្តជឿថ្មីចូលសាសនាចក្រ ឲ្យផ្លាស់ទៅរដ្ឋមិសសួរី ។ សូមអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ៥៥:៤ និង ៥៧:១១–១៣ ដោយរកមើលកិច្ចការពិសេសដែលព្រះអម្ចាស់បានប្រទានដល់វិលលាម ឲ្យបម្រើក្នុងសាសនាចក្ររបស់ទ្រង់ ។ សូមប្រើលិបិក្រម « Authors and Composers » នៅក្នុងសៀវភៅទំនុកតម្កើងដើម្បីស្វែងរកទំនុកតម្កើងដែល វិលលាម ដ័បបុលយូ ហ្វែប្ស បានសរសេរ ដែលបន្តផ្ដល់ពរដល់សាសនាចក្រសព្វថ្ងៃនេះ ។ វិលលាម បានអភិវឌ្ឍជំនាញ និងការអប់រំ ដែលបានជួយគាត់បម្រើព្រះអម្ចាស់ និងអ្នកដទៃតាមរបៀបដ៏មានអត្ថន័យ ។ តើក្មេងជំទង់អាចធ្វើអ្វីខ្លះនៅពេលនេះ ដើម្បីអភិវឌ្ឍជំនាញ ការអប់រំ និងមធ្យោបាយផ្សេងៗដើម្បីជួយពួកគេបម្រើព្រះអម្ចាស់ និងអ្នកដទៃទៀតនៅពេលអនាគត ?


សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80007812_258_564-1